# បុព្វកថា

ខ្ញុំសូមស្វាគមន៍ និងសាទរចំពោះការបោះពុម្ពផ្សាយឆ្នាំទី៣ លេខ១ របស់**ទស្សនាវដ្ដីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្ទែម** ( Cambodian Journal of Education and STEM ) ដែលជាការបោះពុម្ពផ្សាយលើកទី៥ និងមានអត្ថបទស្រាវជ្រាវសរុបចំនួន៧អត្ថបទ។ ចាប់តាំងពីឆ្នាំ២០២៣ ទស្សនាវដ្ដីស្រាវជ្រាវនេះបានបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវសរុបចំនួន៤០អត្ថបទ។ និរន្តរភាពនៃការបោះពុម្ពផ្សាយរបស់ទស្សនាវដ្ដីស្រាវជ្រាវនេះ ជាសាក្ខីភាពនៃកិច្ចខិតខំប្រឹងប្រែង របស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការលើកកម្ពស់ការស្រាវជ្រាវនិងបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវជាភាសាខ្មែរ ទាំងបរិមាណ និងគុណភាព ព្រមទាំងបង្កើនធនធានសិក្សាជាភាសាខ្មែរដែលបើកទូលាយសម្រាប់បម្រើឱ្យការរៀននិងបង្រៀន ការស្រាវជ្រាវ និងការរៀបចំគោលនយោបាយនៅឧត្តមសិក្សា និងក្នុងប្រទេសកម្ពុជាទាំងមូល។

តាមរយៈការអនុវត្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ទាំងបួនដំណាក់កាល ចាប់តាំងពីឆ្នាំ២០១៤ រហូតមកដល់បច្ចុប្បន្ន ក្រសួងយអប់រំ យុវជន និងកីឡា បានយកចិត្តទុកដាក់យ៉ាងខ្លាំងលើការលើកកម្ពស់សមត្ថភាពស្រាវជ្រាវនិងនវានុវត្តន៍ ដោយកសាងប្រព័ន្ធអេកូឡូស៊ីស្រាវជ្រាវនៅឧត្តមសិក្សាដែលគាំទ្រដល់គ្រឹះស្ថានឧត្តមសិក្សាសម្រាប់ធ្វើការស្រាវជ្រាវឱ្យឆ្លើយតបនឹងតម្រូវការរបស់ទីផ្សារ សហគមន៍ និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ។ សមិទ្ធផលរយៈពេល១០ឆ្នាំកន្លងមកនេះរួមមាន ការរៀបចំឯកសារគោលនយោបាយគាំទ្រការស្រាវជ្រាវនិងនវានុវត្តន៍ ក្នុងនោះមាន ក្របខ័ណ្ឌគ្រប់គ្រងការស្រាវជ្រាវនៅគ្រឹះស្ថានឧត្តមសិក្សា, សៀវភៅណែនាំស្ដីពីការគ្រប់គ្រងការស្រាវជ្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សា, សៀវភៅណែនាំស្ដីពីការបង្កើត គ្រប់គ្រង និងអភិវឌ្ឍទស្សនាវដ្ដីស្រាវជ្រាវវិទ្យាសាស្ត្រ, និងសៀវភៅព័ត៌មានស្ដីពីទស្សនាវដ្ដីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្ទែម។ ក្រៅពីនេះ ក្រសួងក៏បានផ្ដោតសំខាន់លើការវិនិយោគលើគម្រោងស្រាវជ្រាវ ជាពិសេសគម្រោងស្រាវជ្រាវដែលផ្សារភ្ជាប់ជាមួយឧស្សាហកម្ម ដែលអាចបង្កើតចេញជាផលិតផលស្រាវជ្រាវ និងអាចប្រើប្រាស់ដោយសហគ្រាសឧស្សាហកម្ម ឬស្ថាប័នរដ្ឋ, ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារបរិក្ខារបម្រើឱ្យការស្រាវជ្រាវ, ការបង្កើតនិងពង្រឹងគុណភាពទស្សនាវដ្ដីស្រាវជ្រាវក្នុងស្រុក ជាពិសេសឈានដល់បានការទទួលស្គាល់ក្នុងលិបិក្រមអាស៊ាន ( Asian Citation Index ), ការបង្កើនការបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវក្នុងទស្សនាវដ្ដីស្រាវជ្រាវក្នុងនិងក្រៅស្រុក ជាពិសេសទស្សនាវដ្ដីស្រាវជ្រាវក្រៅស្រុកដែលបានទទួលស្គាល់ក្នុងលិបិក្រមស្កូប៉ឹស ( Scopus-indexed ), ការតែងតាំងឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំជាលើកដំបូង, ការបង្កើតមជ្ឈមណ្ឌលឧត្តមភាព, ការអភិវឌ្ឍសមត្ថភាពនិងគុណវុឌ្ឍិអ្នកស្រាវជ្រាវ និងអ្នករដ្ឋបាលស្រាវជ្រាវ, ការរៀបចំវេទិកាផ្សព្វផ្សាយ សន្និសីទ ទិវាប្រកួតប្រជែង និងការតាំងពិព័រណ៍លទ្ធផលស្រាវជ្រាវ, និងការបង្កើតថ្នាលឌីជីថលសម្រាប់ចែករំលែកនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រ និងបណ្ឌិត។

ក្នុងនាមក្រសួងអប់រំ យុវជន និងកីឡា ខ្ញុំសូមថ្លែងអំណរគុណ និងសូមកោតសរសើរ ចំពោះថ្នាក់ដឹកនាំក្រសួង ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានឧត្តមសិក្សា ថ្នាក់ដឹកនាំនាយកដ្ឋាន ថ្នាក់គ្រប់គ្រងការិយាល័យ និងមន្ត្រីនៃនាយកដ្ឋានស្រាវជ្រាវនិងនវានុវត្តន៍ និងជាពិសេសក្រុមប្រឹក្សាពិគ្រោះយោបល់ និពន្ធនាយក និពន្ធនាយករង និងក្រុមបច្ចេកទេសនៃទស្សនាវដ្ដីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្ទែម ដែលបានខិតខំប្រឹងប្រែង ប្រកបដោយការប្ដេជ្ញាចិត្ត និងការទទួលខុសត្រូវខ្ពស់ ក្នុងការពិនិត្យ និងរៀបចំបោះពុម្ពផ្សាយទស្សនាវដ្ដីស្រាវជ្រាវជាភាសាខ្មែរ ដ៏មានសារៈសំខាន់នេះឡើង។

ជាទីបញ្ចប់ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ការបោះពុម្ពផ្សាយលើកទី៥ (ឆ្នាំទី៣ លេខ១) របស់ទស្សនាវដ្តីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្នៃមនេះ នឹងក្លាយជាធនធានសិក្សា និងឯកសារស្រាវជ្រាវដ៏មានសារៈសំខាន់ ក្នុងការផ្តល់ចំណេះដឹងថ្មីៗ ផ្អែកលើការស្រាវជ្រាវដែលមានលក្ខណៈវិទ្យាសាស្ត្រ ដល់អ្នកស្រាវជ្រាវ អ្នករៀបចំគោលនយោបាយ សាស្ត្រាចារ្យ គ្រូបង្រៀន និងនិស្សិតកម្ពុជា។

ថ្ងៃ សុក្រ ១១កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែមិថុនា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**